ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆមាសទី១ ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ស្ថានភាពអាកាសធាតុនាដើមរដូវវស្សាមានភ្លៀងធ្លាក់ជាមធ្យមនិងតិចតួចនៅតាមតំបន់នៃរាជធានី ខេត្ត ក្រុង ស្រុក ដោយទទួលឥទ្ធិពលនៃខ្យល់មូសុងរួមជាមួយនឹងខ្យល់កន្ត្រាក់សម្ពាធទាបបក់ពីទិសនិរតី។ ទោះបីជាបរិមាណទឹកភ្លៀងមិនទាន់មានអំណោយផលល្អប្រសើរយ៉ាងណាក៏ដោយ ក៏ប្រជាកសិករទូទាំងប្រទេសបានខិតខំជំរុញការងារបង្កបង្កើនផលគ្រប់មុខដំណាំ ជាពិសេសការចាប់ផ្តើមការងារបង្កបង្កើនផលស្រូវ រដូវវស្សាមានជាអាទិ៍ ការរៀបចំដីភ្ជួររាស់ សាប ព្រោះ ដក ស្ទូង ដោយសម្រេចលទ្ធផលបានប្រមាណ៣៣,២០ភាគរយ នៃផែនការដាំដុះ២.៤១១.២០៧ហិកតា។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០១៤នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន១.១៣៤.៥៥៦ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន១៧៦.៩០៥ហិកតា ស្មើនឹង ១៥,៥៩% និងគ្រឿងយន្តចំនួន៩៧០.២៤៥ហិកតា ស្មើនឹង៨៥,៥២%) តិចជាងឆ្នាំមុនចំនួន១៤០.៤៤៥ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៣២២.៥៨៧ហិកតា

-ផ្ទៃដីសាបសរុបចំនួន២៩.៨៧១ហិកតា តិចជាងឆ្នាំមុនចំនួន២២.២៤៦ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៧០.០២៣ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៨០០.៥២៨ហិកតា ស្មើនឹង៣៣,២០ភាគរយនៃផែនការ២.៤១១.២០៧ហិកតា លើសឆ្នាំមុនចំនួន១២៦.៨៧៩ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន១៧.៩៦៧ហិកតាក្នុងនោះ៖

- ស្រូវស្រាលចំនួន២៨៤.៥៦៤ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៥០.៥៣២ហិកតា) លើសឆ្នាំមុនចំនួន២៩.៩២៣ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន២៩.៣០៨ហិកតា
- ស្រូវកណ្តាលចំនួន២៦៦.២៦៧ហិកតា លើសឆ្នាំមុនចំនួន៩១.៤៨៦ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន២០.១៦២ហិកតា
- ស្រូវធ្ងន់ចំនួន១៧០.៨០១ហិកតា លើសឆ្នាំមុនចំនួន២០.៩៣១ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន២៧.៥៧៨ហិកតា
- ស្រូវចម្ការចំនួន២៧.៩៩០ហិកតា តិចជាងឆ្នាំមុនចំនួន៨.០៣៤ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន១១.៤៣១ហិកតា
- ស្រូវឡើងទឹកចំនួន៥០.៩០៦ហិកតា តិចជាងឆ្នាំមុនចំនួន៧.៤២៧ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន២៨.៤២៨ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

### ១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៥៣៩.១៣៥ហិកតា ស្មើនឹង១០២,១១% នៃផែនការចំនួន៥២៨.០១៨ហិកតា លើសឆ្នាំមុនចំនួន៦៩.៦៩៣ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីដាំពោតចំនួន៧៥.០២៧ហិកតា (ក្នុងនោះពោតក្រហម៥៨.៨១២ហិកតា) តិចជាងឆ្នាំមុន២៣.០៥២ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន៤០៩.៩៧៨ហិកតា លើសឆ្នាំមុន៩៨.៩៧៥ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន២.២៩២ហិកតា តិចជាងឆ្នាំមុន៧០៦ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន១៩.១៨៤ហិកតា លើសឆ្នាំមុន៥៦៨ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន៣២.៦៥៤ហិកតា តិចជាងឆ្នាំមុន៦.០៩២ហិកតា ។

### ១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន៦៥.៣៨៧ហិកតា ស្មើនឹង៤១,៦៦% នៃផែនការ១៥៦.៩៦៥ហិកតា លើសឆ្នាំមុន៦.១៥៨ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន១១.០៩៧ហិកតា តិចជាងឆ្នាំមុន២.២០៤ហិកតា

-ផ្ទៃដីសណ្តែកសៀងចំនួន៥.៨៥១ហិកតា លើសឆ្នាំមុន៤.៣១៧ហិកតា

-ផ្ទៃដីល្ងចំនួន៣៣.៩៨១ហិកតា លើសឆ្នាំមុន៤.៩៤៤ហិកតា

-ផ្ទៃដីអំពៅចំនួន១៤.២១០ហិកតា តិចជាងឆ្នាំមុន៩៥០ហិកតា

-ផ្ទៃដីក្រចៅចំនួន១៧១ហិកតា តិចជាងឆ្នាំមុនចំនួន៤៥ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន៧៧ហិកតា តិចជាងឆ្នាំមុន៤ហិកតា។

### ១.៤ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ មានបរិមាណ១៧៧.៩២៨តោន ដែលមានការកើនឡើងចំនួន១.៩៦៩តោន(+១%) លើសបរិមាណនាំចេញក្នុងឆមាសទី១ឆ្នាំ២០១៣ (ដែលមានតែ១៧៥.៩៥៩តោន) ដោយឡែកបរិមាណនាំចេញក្នុងខែមិថុនា ឆ្នាំ២០១៤នេះមាន២៩.៦៦៦តោន ដែលមានការកើនឡើងចំនួន៥៦១តោន(+២%)លើសបរិមាណនាំចេញក្នុងខែមិថុនា ឆ្នាំ២០១៣ (ដែលមានតែ២៩.១០៥តោន) និងនាំចេញទៅកាន់ទិសដៅចំនួន៥៤ប្រទេស។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអេជីខកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៩៣,៤៥ | ៥០,០០ |
| | សរុប I | ៤០៦,៦០ | ៣៤៤,៣១ | ១៩៣,៤៥ | ៥០,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,០០ | ៥.៣២៧,០៥ | ៧.៤១២,៤២ | ២.៦៦៨,៨៦ |
| ២ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (តនគិរី) | ៣៦៧,៣៥ | ១.៦២៥,៩០ | ៤១៥,៨៣ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៩០ | ៨៨៥,០១ | ៣៦៩,១០ | ២០៨,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.០៥៨,២៧ | ១.៨៧១,៧២ | ១.១២៥,៩០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.២៥៩,០៨ | ១.៧៧៥,៨១ | ៦២៩,៦០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្សរីសសស់ (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ៨០៥,៩៦ | ៦៤៦,៩០ |
| ៧ | ក្រុមហ៊ុន អានប៉ាឌីគ្រុប (ពាមជាំង) | ២.១៧៧,០៤ | ១.១៥៩,០០ | ៦៥៧,៤៣ | ៥១០,០០ |

| | | | | | |
|---|---|---|---|---|---|
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្ដូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៦០៧,២៩ | ៣៦០,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.៥៧០,៦៣ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.០៧៧,៩២ | ២.១៣៤,១៦ | ១.៤៤០.០០ |
| សរុប II | | ២៦.៩៨២,២៩ | ២៧.៤១៣,៤០ | ១៦.០៤៩,៧២ | ៧.៥៨៩,១៦ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៨៤.៩០២,០០ | ២០.៩៥៣,០០ | ២០.៩៥៣,០០ |
| សរុប III | | ៦១.២៧១,០០ | ២២០.៣៤៨,០០ | ២០.៩៥៣,០០ | ២០.៩៥៣,០០ |
| សរុប I+II+III | | ៨៨.៦៥៩,៨៩ | ២៤៨.១០៥,៧១ | ៣៧.១៨៦,១៧ | ២៨.៥៩២,១៦ |

### ២.២ ការងារស្រាវជ្រាវ ការផ្សព្វផ្សាយ បណ្ដុះបណ្ដាល និងសកម្មភាពផ្សេងៗទៀត

-បណ្ដុះបណ្ដាលបច្ចេកទេសចៀរជ័រដល់អ្នកចៀរជ័រកៅស៊ូនៅប្រទេសមីយ៉ាន់ម៉ា

-ដឹកនាំការសរសេរសារណាបទបញ្ចប់ការសិក្សានិស្សិតចំនួន១១នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង សាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប

-វាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅចម្ការកៅស៊ូក្រែក ខេត្តត្បូងឃ្មុំ បានចំនួន៤ឡូត៍ ពិសោធន៍នៅលើផ្ទៃដី២០ហិកតា

-ធ្វើតេស្តភាគសំណាកយថាប្រភេទបានចំនួន១៣៦ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃកៅស៊ូរបស់រោងចក្រក្រុមហ៊ុនចម្ការកៅស៊ូ

-ធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១១០ជាមួយ IRA ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់ចំពោះកៅស៊ូ TSR

-បំបៅកូនកៅស៊ូចំនួន៣១.០៣៦កូន ដែលមាន៥៣ពូជ និងជម្រះស្មៅរវែករងកៅស៊ូដាំឆ្នាំ២០០៨-២០១៣បានចំនួន១៨៧,៥០ហិកតា។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៣២៤ក្បាល ក្នុងនោះជ្រូកបាចំនួន១៣ក្បាល ជ្រូកមេចំនួន១០២ក្បាល និងកូនជ្រូកចំនួន២០១ក្បាល

-គោសរុបចំនួន២០១ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៥១ក្បាល គោបៅដោះចំនួន៤៦ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន១៧៥.៧១៤ក្បាល ជំងឺអុតក្ដាមចំនួន១៣.៧៧៨ក្បាល និងជំងឺបូសខ្យល់ចំនួន២.៨៨៥ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៩១.២៥៦ក្បាល ជំងឺប៉េស្តចំនួន៧៥.៨៥៣ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៥០.៣២២ក្បាល ជំងឺអុតក្ដាមចំនួន៤.៥៧៤ក្បាល ជំងឺអូហ្យេស្គីចំនួន៧.០៦១ក្បាល ជំងឺរាគកូនជ្រូកចំនួន១៣.៦០៧ក្បាល ជំងឺកញ្ច្រឹលចំនួន១.១៦១ក្បាល ជំងឺជាតិដែកចំនួន៨.៨០៦ក្បាល និងជំងឺផ្លូវដង្ហើមចំនួន១.៤១៥ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន១០២.៩៥៩ក្បាល ជំងឺញីវកាសចំនួន១៨៧.៦៧១ក្បាល ជំងឺអាសន្នរោគចំនួន១៩៦.៥៨៣ក្បាល ជំងឺហ្គុមបូរូចំនួន១.៩៣២ក្បាល និងជំងឺប៉េស្តទាចំនួន៧៩.០១១ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្ដាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-បានពិនិត្យវត្ថុវិភាគសរុបចំនួន៤.០៩៨សំណាក

-បានពិនិត្យវត្ថុវិភាគសរុបចំនួន១០៣សំណាក។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន៤៨ករណី មកពីតាមបណ្តារាជធានី ខេត្ត វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងក្រសួងសុខាភិបាល សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្តាសាយបក្សី

-តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស

-ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ មានករណីផ្ទុះជំងឺផ្តាសាយបក្សីប្រភេទ H5N1 ចំនួន៥ករណីគឺៈ នៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ភូមិកណ្តាល ឃុំវត្តអង្គខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត និងវិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រកាសរំសាយតំបន់ជំងឺផ្តាសាយបក្សីចំនួន៤កន្លែង គឺនៅភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ភូមិកណ្តាល ឃុំវត្តអង្គខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត និងភូមិទួលសង្កែ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល និងភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន២លើក ក្របីចំនួន២លើក ជ្រូកចំនួន៦០០ក្បាល មាន់ចំនួន៨៦៧ក្បាល ទាចំនួន៣៥២លើក កន្លែងពិឃាតមាន់ចំនួន៤០លើក កន្លែងលក់មាន់ចំនួន៤១លើក ទ្រុងចិញ្ចឹមចំនួន១.២០៦លើក បរិវេណភូមិចំនួន៩២លើក សត្តឃាតដ្ឋានចំនួន៣៤៧លើក ផ្លូវជាតិចំនួន២៦៣លើក និងកន្លែងផ្ទុះជំងឺចំនួន០១លើក

-ចាត់ក្រុមអន្តរាគមន៍ចុះប្រតិបត្តិការជាប្រចាំដើម្បីធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាងដោយខុសច្បាប់ ដោយបានអនុវត្តវិធានការបសុពេទ្យជាក់ស្តែង ព្រមទាំងបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៣.៥ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន៨៣១ឡ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជនៈ ឈើហ៊ុបមូលសរុបចំនួន ៨៧.៥៦០,៦៧៧ម៣ ឈើអារចំនួន៥១៣,៧៩៥ម៣ ឈើជ្រុងចំនួន៣.៩៤២,០៤២ម៣ សសរជ្រុងចំនួន២៧,៣៣៥ម៣ ឈើឃ្នាបចំនួន១២,៧៩៥ម៣ កូនឈើចំនួន១.១៩៨.៤៧២ដើម អុសចម្រុះចំនួន៨៩.២១៥ស្ទែរ ជ័រទឹកចំនួន៥៣៨,៦៤២តោន ផ្តៅចំនួន២៤តោន សសរចំនួន១.៣៤៥ដើម ឫស្សីចំនួន៦៤២,៥២៣តោន និងគ្រាប់សំរ៉ែងចំនួន២,០៦២តោន

-សហគមន៍ព្រៃឈើនៅទូទាំងប្រទេសមានចំនួន៤៧៩សហគមន៍ ដែលអង្គភាពជំនាញកំពុងខិតខំពង្រឹងសហគមន៍ទាំងនោះតាមរយៈការទាក់ទាញជំនួយបច្ចេកទេសពីដៃគូដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍ឲ្យអនុវត្តការធ្វើកសិកម្មចម្រុះបន្ថែមទៀត ដោយមិនអាស្រ័យទៅលើតែផល អនុផលព្រៃឈើ ព្រមទាំងចូលរួមថែរក្សា ការពារព្រៃឈើនៅក្នុងសហគមន៍ប្រកបដោយនិរន្តរភាព។

### ៤.២ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វឱ្បីកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួនប្រមាណ១៨៦ប្រភេទ ស្មើនឹង៨៩០.៤២៧ក្បាល

-ចុះស្រាវជ្រាវសត្វព្រៃនៅក្នុងព្រៃការពារព្រះវិហារចំនួន០២លើក និងព្រៃការពារមណ្ឌលគិរីចំនួន០២លើក ដោយរកឃើញសត្វព្រៃសំខាន់ៗដូចជា ដំរី ខ្ទីង ទន្សោង ប្រើស ត្រយងយក្ស ខ្លាឃ្មុំ ត្រដល់តូច ឈ្លូស ប្រើស និងក្ងោក មាន់ព្រៃ ត្រកួត និងអណ្តើក

-រៀបចំអាហារដ្ឋានត្មាតចំនួន១៩លើក នៅតំបន់អភិរក្សជីវចម្រុះសៀមប៉ាងនិងព្រៃការពារព្រះវិហារ ស្ទឹងត្រែង និងក្រចេះ ដោយរាប់ឃើញត្មាតសរុបប្រមាណ២០៨ក្បាល

-ការពារសម្បុកត្រយ៉ងចង្កក ស ចំនួន១២០ក្បាល ត្មាតចំនួន១៤ក្បាល រំពេទន្លេចំនួន៩៦ក្បាល ត្រដក់តូចចំនួន៩៦ក្បាល ត្រយ៉ងយក្សចំនួន០៦ក្បាល និងវនាលពណ៌ចំនួន៥៨ក្បាល នៅតំបន់សៀមប៉ាងភាគខាងលិច អាងត្រពាំងថ្ម តំបន់ព្រៃការពារព្រះវិហារ និងតំបន់ទន្លេមេគង្គលើ។

## ៤.៣ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន៩១លើក ស្តីពីច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋាននានាពីសារៈសំខាន់សត្វព្រៃ និងជីវចម្រុះ កិច្ចការពារសត្វព្រៃនិងជីវចម្រុះ ការពារសម្បុកសត្វ ការអភិរក្ស ការប្រើប្រាស់ធនធានធម្មជាតិ និងលិខិតបទដ្ឋាននានាទាក់ទងដល់វិស័យព្រៃឈើនិងសត្វព្រៃ និងទប់ស្កាត់ការទន្ទ្រានយកដីព្រៃ ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន២.៩១២នាក់ ស្ត្រី១.១១៨នាក់។

## ៤.៤ កសិដ្ឋានចិញ្ចឹម ការបន្ពាក់ពូជស្ទាក្ទាម និងការសង្គ្រោះសត្វព្រៃ

-ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន៣២៨ក្បាល សត្វកើតថ្មីចំនួន៣២ក្បាល សត្វដោះលែងចំនួន៣៣៩ក្បាល សត្វស្លាប់ចំនួន៤៨ក្បាល ព្យាបាលសត្វចំនួន១៣៥ក្បាល យកសំណាកទៅពិសោធន៍ចំនួន៥១ក្បាល ធ្វើឲ្យសន្លប់ចំនួន១៣១ក្បាល ទម្លាក់សត្វល្អិតចំនួន៥៦ក្បាល វះកាត់សាកសពសត្វចំនួន២៩ក្បាល ដាក់លេខកូដចំនួន២៩ក្បាល ចាក់វ៉ាក់សាំងចំនួន៥៤៣ក្បាល សាងសង់របងហ៊ុំព័ទ្ធនិងទ្រុងសត្វថ្មីចំនួន៣.៤០០ម² ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៣៨ម² ជួសជុលផ្លូវចំនួន៧៣.៤៧០ម² សាងសង់សំណង់ផ្សេងៗចំនួន៩២ម² ថ្នាំអនាម័យព្រៃចំនួន១៥៦.៨៦៦ម² ដាំកូនឈើចំនួន៤.៨៦៩ដើម បណ្តុះផ្កាលម្អចំនួន៩.០៧៧ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៣.៤០៣នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្ទាមមេ-បាពូជ និងកូនស្វាក្ទាមចំនួន៥៧.០០៤ក្បាល។

## ៤.៥ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-បន្តថែរក្សាកូនក្រពើចំនួន២៤ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង។

## ៤.៦ ការងារដាំដើមឈើ

-ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានឈូសឆាយដីព្រៃសរុបចំនួន៦.៩២១ហិកតា ដាំឈើជាចម្ការបានចំនួន៥០ហិកតា បណ្តុះកូនឈើចំនួន៣.៩៣២.១១៩ដើម និងចែកចាយចំនួន១៥១.០៣៤ដើម។

## ៤.៧ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើកែច្នៃគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០៤ ដែលមានបរិមាណឈើកែច្នៃចំនួន ៦៤.០៨០,០០ម³ ឈើអាកាស្យាអារកែច្នៃចំនួន២០០ម³ និងឈើអាកាស្យាកាត់ជាកង់ៗចំនួន៥០០ស្ទែរ

-ផ្តល់គោលការណ៍នាំចេញផលិតផលឈើកែច្នៃនិងផលិតផលឈើជាំជូនក្រុមហ៊ុនចំនួន៥ ដែលមានបរិមាណឈើកែច្នៃចំនួន១.៩២៥,៤០៨ម³ ចំណិតឈើអាកាស្យានិងប្រេងខ្យល់ចំនួន១២២.៤៥៥,៤៧៨តោន និងដើមចន្ទន៍ក្រស្នាចំនួន១២.២០០ដើម

-ទទួលប្រកាសអនុញ្ញាតឲ្យបង្កើតរោងម៉ាស៊ីនកែច្នៃឈើចំនួន០១ច្បាប់និងពន្យារសុពលភាពជូនក្រុមហ៊ុនចំនួន៤ច្បាប់

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០២ស្មើនឹង៣១៩សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន៥១.០៩១,៣៣៥ម$^3$ ឈើអាកាស្យាកែច្នៃចំនួន៦៣,២០០ម$^3$ និងឈើអាកាស្យាកាត់ជាកង់ៗចំនួន១៦១,៤៨០ស្ទែរ

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន១ស្មើនឹង៣សន្លឹក ដែលមានបរិមាណឈើចំនួន១៥៤ម$^3$ ឈើអាកាស្យាកែច្នៃចំនួន៦៣,២០០ម$^3$ និងឈើអាកាស្យាកាត់ជាកង់ៗចំនួន១៦១,៤៨០ស្ទែរ។

### ៤.៨ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិចំនួន៣៧.៦១៧.៦១០.៩១៧រៀល និងផ្តល់សេវាសាធារណៈចំនួន៧៣៤.៥៣៩,២១ដុល្លារ និង៣២.៣៧០.៥១៤.៨៥៦រៀល។

### ៤.៩ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសសរុបចំនួន១.១០៤ករណី ដោយបញ្ជូនទៅតុលាការសរុបចំនួន៨៧២ករណី និងពិន័យអន្តរការណ៍ចំនួន២៣២ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៧១០,៤៧៦ម$^3$ ឈើអារចំនួន២.១១៤,១០៦ម$^3$ ឈើក្រាក់គ្រញូងចំនួន៨៩,៣១៥ម$^3$និង៣.២៧៥គ.ក្រនិង៤ដុំ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដកហូតដីព្រៃឈើចំនួន១.៥៥៦,៥៣៥ហិកតា។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន២៤.០០០តោន ស្មើ១៦០% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១១.០០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ សរុបបានចំនួន១៨០.០០០តោន ស្មើ៤៦,១៥% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ សរុបបានចំនួន៥៥.០០០តោន ស្មើ៣០,៥៦% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន ។

#### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៤

- អនុវត្តសរុបចំនួន៥៣.០០០តោន ស្មើ៤៨,១៨% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន។

### ៥.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន៤៩.០០០តោន ស្មើ៤៩% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧.០០០តោន

-ការចិញ្ចឹមក្រពើ សរុបបានចំនួន១៧០.០០០ក្បាល ស្មើ៥៦,៦៧% នៃផែនការ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ សរុបបានចំនួន៨០.០០០.០០០កូន ស្មើ៤៤,៤៤% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ សរុបបានចំនួន៣៧.០០០តោន ស្មើ២៤,៦៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ សរុបបានចំនួន៥.៥០០តោន ស្មើ៦៨,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨០០តោន

-ការផលិតទឹកត្រី សរុបបានចំនួន៤៥.០០០.០០០លីត្រ ស្មើ៧៥% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ សរុបបានចំនួន៥.៥០០តោន ស្មើ២៧,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១.០០០តោន

-ផលនេសាទកែច្នៃ សរុបបានចំនួន២.៨០០តោន ស្មើ២៨% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន១.១០០ករណី ដែលកើតមាននៅតំបន់ទឹកសាប១.០៦០ករណី និងតំបន់សមុទ្រ ៤០ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៦៨ករណី គឺតំបន់ទឹកសាបថយចុះ៣៦៦ករណីនិងតំបន់សមុទ្រថយចុះ២ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលចំណូល

-ចំណូលពីវិស័យជលផល សរុបបានចំនួន១.៩៥៦.៥៩៣.៥៩៤រៀល ស្មើ៦៤,៣១% នៃផែនការ ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥៩២.១៣៦.៨៩៧រៀល។

## ៦ ផ្នែកនីតិកម្មកសិកម្ម

### ៦.១ ការងារគ្រប់គ្រងកម្មសម្ភារកសិកម្ម និងការងារមន្ទីរពិសោធន៍

-ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ការនាំចូលសម្ភារកសិកម្មមានថ្នាំកសិកម្មចំនួន១៧.២០០,១៣តោននិង ៣១០.៧៨៨លីត្រ ជីកសិកម្មចំនួន៥២៤.៥៣៦,៤០តោននិង១៩០.០០០លីត្រ ចំណីសត្វចំនួន១៣៦.៥២៩តោន វត្ថុធាតុដើមសម្រាប់ផលិតចំណីសត្វចំនួន១៧៨.១៨០,៣០តោន បសុឱសថចំនួន៥៨.២៤០,១៩តោន ពូជដំណាំចំនួន៤.៥៦៦តោន និងបរិក្ខារបសុពេទ្យចំនួន១៣មុខនិង៨៩,០១៥តោន

-ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មចំនួន០៨ករណី ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មនិងថ្នាំកសិកម្មចំនួន៥៣ករណី ការអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្មចំនួន៣៧ករណី និងការអនុញ្ញាតប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន០១ករណី

-ធ្វើវិភាគសារធាតុបន្ទាប់បន្សំ (Micro Elements) លោហៈធ្ងន់ធ្ងរនៅក្នុងជីកសិកម្មដែលស្នើសុំចុះបញ្ជីកាបានចំនួន២៤៧សំណាក ក្នុងនោះរកឃើញសារធាតុលោហៈធ្ងន់លើសពីស្តង់ដារកំណត់ចំនួន០៦សំណាក។

### ៦.២ ការងារអភិវឌ្ឍន៍បទដ្ឋានគតិយុត្ត និងផ្សព្វផ្សាយ

-ចូលរួមអភិវឌ្ឍន៍លិខិតបទដ្ឋានគតិយុត្តក្នុងក្រសួងចំនួន០៩ច្បាប់

-រៀបចំប្រកាសលេខ១៩៩ ប្រក.កសក ស្តីពី "នីតិវិធីពិន័យអន្តរការណ៍លើបទល្មើសនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម"

-រៀបចំសេចក្តីព្រាងសារាចរអន្តរក្រសួងស្តីពី "ទម្រង់ឯកសារសម្រាប់នគរបាលយុត្តិធម៌នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើប្រាស់ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម

-រៀបចំនូវសេចក្តីព្រាងប្រកាសស្តីពី "នីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម" ត្រៀមដាក់ប្រជុំក្រុមការងារ

-អញ្ជើញអាជីវករជីកសិកម្មដែលមានទីតាំងនៅរាជធានីភ្នំពេញ និងខេត្តកណ្តាលមកប្រជុំណែនាំអំពីនីតិវិធីក្នុងការធ្វើពាណិជ្ជកម្ម ស្តុកទុក វេចខ្ចប់ជាថ្មី និងការដឹកជញ្ជូនជីកសិកម្ម

-ធ្វើការប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មដល់អាជ្ញាធរដែនដី និងសមត្ថកិច្ចច្រកទ្វារព្រំដែននៅក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ និងបានផ្តល់ជូនឯកសារពាក់ព័ន្ធក្នុងការគ្រប់គ្រងសម្ភារកសិកម្មដល់អ្នកចូលរួម។

## ៦.៣ ការងារត្រួតពិនិត្យនិងអនុវត្តច្បាប់

-ចុះត្រួតពិនិត្យការនាំចូលសម្ភារកសិកម្មបានចំនួន១២ក្រុមហ៊ុន ក្នុងនោះមានជីកសិកម្ម ថ្នាំកសិកម្ម ចំណីសត្វ និងបសុឱសថ

-ស្នើសុំវិធានការទណ្ឌកម្មចំពោះក្រុមហ៊ុនចំនួន០៤ក្រុមហ៊ុននិងពិន័យអន្តរការណ៍ជាប្រាក់ចំនួន៣២.០០០.០០០រៀល ចំពោះអាជីវករផ្គត់ផ្គង់ចែកចាយចំនួន០៣ និងពិន័យអន្តរការណ៍ជាប្រាក់ចំនួន១៤.០០០.០០០រៀល

-ត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារកសិកម្មលក់ដុំ លក់រាយសម្ភារកសិកម្ម នៅក្នុងខេត្តគោលដៅចំនួន១២ និងចាត់វិធានការច្បាប់ដោយកែតម្រូវផ្ទាល់មាត់ចំនួន៦០ករណី និងចេញលិខិតព្រមានចំនួន០២ករណី។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ទទួលជួបធ្វើបទបង្ហាញអំពីលទ្ធផលការងារពិសោធន៍ស្រាវជ្រាវនិងពិភាក្សា ព្រមទាំងផ្តល់ប្រឹក្សាចំនួន៣៣លើក ជាមួយគណៈប្រតិភូ ភ្ញៀវជាតិនិងអន្តរជាតិចំនួន១២៣នាក់

-ធ្វើពិសោធន៍ចំនួន៦១ប្រភេទ នៅ៦៩៣កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញចំនួន៥២៨កន្លែង

-ធ្វើអង្កេតបានចំនួន១១ប្រភេទដោយបានធ្វើសម្ភាសន៍កសិករចំនួន១.២០០នាក់

-ធ្វើការបែងចែកសៀវភៅឯកសារនានាបានចំនួន១.៣៨៨ច្បាប់ និងព្រឹត្តិបត្រព័ត៌មានកសិករចំនួន២.៥០០ច្បាប់ ជូនអង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធ ជាពិសេសដល់កសិករ

-ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន១៩៣.៥០០នាក់ គិតជាមធ្យមប្រមាណ១.០៧៥នាក់ក្នុងមួយថ្ងៃ កើនលើសមធ្យមភាគប្រចាំឆ្នាំ២០១៣ចំនួន១៧៩នាក់ក្នុងមួយថ្ងៃ។

## ៨ ផ្នែករដ្ឋបាល

-ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន២.៨០៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន២.០៦៧ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៦៦៧ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន៤.៣៣១ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន៣១២ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន៤១៩ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦៨៦នាក់ នារីចំនួន១.២៧៧នាក់ ស្មើនឹង១៩% ក្នុងនោះ៖

-អង្គភាពថ្នាក់កណ្តាលចំនួន៤.០៨៤នាក់ ក្នុងនោះនារីចំនួន៧៤៥នាក់ ស្មើនឹង១៨,២៤%

-អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦០២នាក់ ក្នុងនោះនារីចំនួន៥៣២នាក់ ស្មើនឹង២០,៤៤%

-ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌចំនួន៤៧នាក់ ក្នុងនោះបោះបង់ការងារចំនួន៨នាក់ សុំលាឈប់ពីការងារចំនួន១២នាក់ និងមរណភាពចំនួន២៧នាក់

-ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន៨នាក់ ផ្ទេរចូលក្រសួងចំនួន៩នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន៥២នាក់

-ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៣៤នាក់

-ថ្នាក់ដឹកនាំមន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា និងទស្សនកិច្ចសិក្សាបានចំនួន២៨៨នាក់ នៅក្នុងប្រទេសចំនួន២៩ ក្នុងនោះចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលខ្លីចំនួន១៤៨នាក់ និងរយៈពេលវែងចំនួន៩នាក់

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការក្របខណ្ឌថ្មី និងបានរៀបចំធ្វើនិយតកម្មដល់មន្ត្រីរាជការថ្នាក់កណ្តាល និងរាជធានី ខេត្ត

-ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.២៦៣នាក់(ស្រី៤៤៣នាក់) ក្នុងនោះមាននិស្សិតអាហារូបករណ៍ និស្សិតបង់ថ្លៃ និងនិស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យ ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សាលាជាតិកសិកម្មព្រែកលៀបបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងបណ្តុះបណ្តាលបច្ចេកទេសដាំដុះឈើហូបផ្លែនិងបន្លែ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនហ៊ួរវេង នៃខេត្តក្វាងស៊ី ។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៥៨នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖

-និស្សិតអាហារូបករណ៍សរុប១.២៩៤នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផលដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់ (ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមស្ថានភាពការងារបង្កបង្កើនផលស្រូវនាដើមរដូវវស្សាឆ្នាំ២០១៤ ត្រូវបានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមនិងតិចតួចគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន៣៣,២០ភាគរយ នៃផែនការនិងមានសភាពលឿនជាងឆ្នាំមុន(រយៈពេលដូចគ្នា) ក្នុងនោះមានខេត្តអនុវត្តលឿនជាងគេគឺខេត្តបន្ទាយមានជ័យសម្រេចបាន៨៥,២០ភាគរយ។ ទន្ទឹមនឹងនោះ ប្រជាកសិករកំពុងបន្តយ៉ាងសកម្មក្នុងការងារបង្កបង្កើនផលដំណាំរដូវវស្សា ជាពិសេសខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប ព្រោះ និងដក ស្ទូង ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាននិងកំពុងចាត់វិធានការជាបន្តបន្ទាប់ ដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ ដោយបានចាត់ក្រុមការងារចុះអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងបានចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានីខេត្ត។

ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការត្រូវតែខិតខំបន្តសកម្មភាពដូចឆ្លៀងរលើម ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និង

បទដ្ឋានផ្សេងៗ។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## V- ទិសដៅអនុវត្តបន្ត

-តាមដាននិងអន្តរាគមន៍ចំពោះការជុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

-តាមដានចលនានាំចេញស្រូវនិងអង្ករ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអត្តុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មច្ឆាជាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសត្វចង្រៃបំផ្លាញដំណាំផ្សេងៗ។ល។

-បន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ

និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្លាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចភ្លៀងរលឹម

-ទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-ទំនាក់ទំនងនិងសហការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីទទួលបានជំនាញការមកជួយរៀបចំយន្តការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀតនិងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្មនិងព្រៃឈើអាស៊ានឆ្នាំ២០១៤ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន និងត្រៀមចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរ

តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**